


## ការបញ្ចប់កិច្ចសន្យាការងារមុនពេលកំណត់

ភាគីណាដែលមានបំណងចង់បញ្ចប់កិច្ចសន្យាការងារមុនពេលកំណត់ **ភាគីនោះត្រូវជូនដំណឹង ទៅភាគីម្ខាងទៀតក្នុងកំឡុងពេលមួយខែឬជំនួសដោយការផ្តល់ជាការបង់សំណងសម្រាប់រយៈ ពេលមួយខែ** ទៅភាគីម្ខាងទៀត។



ការផ្តល់សំណងនៅពេលបញ្ចប់កិច្ចសន្យាការងារមុនពេលកំណត់ រួមមាន ៖

- ផ្តល់បង្គ្រប់ប្រាក់ឈ្នួលដែលមិនទាន់បានផ្តល់ឱ្យ
- ផ្តល់ជាការបង់សំណងជំនួសឱ្យការជូនដំណឹង
- ផ្តល់ប្រាក់ដែលគិតពីការសល់ច្បាប់ប្រចាំឆ្នាំដែលអ្នកជួយធ្វើការមិនបានសុំ
- ការទូទាត់ប្រាក់សម្រាប់ការបម្រើការងាររយៈពេលវែង /ការទូទាត់ប្រាក់បំណាច់ការងារ ប្រសិនបើសមស្រប និង
- ផ្តល់ប្រាក់លើការចំណាយដទៃទៀត ដូចជាការត្រឡប់មកមាតុភូមិវិញដោយឥតគិតថ្លៃ ការហូបចុក និងថ្លៃធ្វើដំណើរជាដើម ។



## ការទូទាត់ប្រាក់បំណាច់ការងារ

អ្នកជំនួយការងារផ្ទះនៅបរទេសមានសិទ្ធិទទួលបានការទូទាត់ប្រាក់បំណាច់ ការងារប្រសិនបើគាត់ ៖

- **បានបម្រើការងារមិនតិចជាង 24 ខែ** ជាមួយនិយោជកតែម្នាក់ មុនពេលបញ្ចប់កិច្ចសន្យា
- ត្រូវបាននិយោជកបញ្ឈប់ឬមិនបន្តកិច្ចសន្យាឱ្យដោយសារតែមូលហេតុមិនត្រូវការគាត់ឱ្យ ធ្វើការបន្តទៀត។





## ការទូទាត់ប្រាក់សម្រាប់ការបម្រើការងាររយៈពេលវែង

អ្នកជំនួយការងារផ្ទះនៅបរទេសមានសិទ្ធិទទួលបានការទូទាត់ប្រាក់សម្រាប់ ការបម្រើការងាររយៈ ពេលវែង ប្រសិនបើគាត់បាន **បម្រើការងារមិនតិចជាង 5 ឆ្នាំ** ជាមួយនិយោជកតែម្នាក់មុនពេលបញ្ចប់កិច្ចសន្យា និងបានបំពេញលក្ខណ្ឌដូចខាងក្រោម៖

- ត្រូវបានបញ្ឈប់ពីការងារឬកិច្ចសន្យាមិនត្រូវបានបន្តដោយសារមូលហេតុផ្សេងក្រៅពីការប្រព្រឹត្តិ កំហុសធ្ងន់ធ្ងរ ឬការឈប់ត្រូវការគាត់ឱ្យធ្វើការបន្តទៀត
- លាលែងពីការងារដោយសារសុខភាពមិនល្អ
- ការលាលែងពីការងារដោយសារអាយុច្រើន (ពោលគឺ មានអាយុ 65 ឡើងទៅ)
- ទទួលមរណភាពនៅកំឡុងពេលបម្រើការងារ ។

## ចំនួនប្រាក់បំណាច់ការងារ ឬប្រាក់សម្រាប់ការបម្រើការងាររយៈពេលវែង



ប្រាក់ឈ្នួលប្រចាំខែ x 2/3 x ឆ្នាំដែលបានបម្រើការងារ

សម្រាប់ឆ្នាំដែលមិនទាន់ចប់គួរត្រូវបានគណនាតាមសមាមាត្រ ។

អ្នកជំនួយការងារផ្ទះនៅបរទេស មានសិទ្ធិទទួលបានតែប្រាក់បំណាច់ការងារ ឬប្រាក់បម្រើការងាររយៈពេលវែងតែមួយប៉ុណ្ណោះ ។

ព័ត៌មានខាងលើត្រូវបានផ្តល់ជូនសម្រាប់ការគូសបញ្ជាក់បទប្បញ្ញត្តិច្បាប់និងបទប្បញ្ញត្តិនៃកិច្ច សន្យាសំខាន់ៗ ដែលជាទូទៅ គឺជាបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងអ្នកជំនួយការងារផ្ទះនៅបរទេស។

សម្រាប់ព័ត៌មានលម្អិតអំពីសិទ្ធិនិងផលប្រយោជន៍ការងាររបស់អ្នកដោយផ្តោតទៅលើ“ការណែនាំ ជាក់ស្តែងសម្រាប់ការងាររបស់អ្នកជំនួយការងារផ្ទះនៅបរគេស” ឬ “ការណែនាំច្បាស់លាស់អំពី ច្បាប់ការងារ” ដែលអាចស្វែងរកបាននៅការិយាល័យសាខារបស់ផ្នែកទំនាក់ទំនងការងារនៃក្រសួងការងារ។



## ខ្សែទូរស័ព្ទសាកសួរបន្ទាន់

(ខ្សែទូរស័ព្ទនេះ ត្រូវបានគ្រប់គ្រងដោយ “1823”)

2717 1771

2157 9537 (ខ្សែទូរសព្ទបន្ទាន់ដែលផ្តល់សម្រាប់អ្នកជំនួយការងារផ្ទះនៅបរទេស)



## អាសយដ្ឋានគេហទំព័រ៖

www.labour.gov.hk

www.fdh.labour.gov.hk

## ការសាកសួរដោយផ្ទាល់ទៅកាន់ការិយាល័យផ្នែកទំនាក់ទំនងការងារ៖

| HONG KONG | |
|---|---|
| **Hong Kong East**<br>12/F., 14 Taikoo Wan Road, Taikoo Shing, Hong Kong. | **Hong Kong West**<br>3/F., Western Magistracy Building, 2A Pokfulam Road, Hong Kong. |
| **KOWLOON** | |
| **Kowloon South**<br>2/F., Mongkok Government Offices, 30 Luen Wan Street, Mong Kok, Kowloon. | **Kowloon West**<br>Room 1009, 10/F., Cheung Sha Wan Government Offices, 303 Cheung Sha Wan Road, Sham Shui Po, Kowloon. |
| **Kowloon East**<br>UGF, Trade and Industry Tower, 3 Concorde Road, Kowloon. | **Kwun Tong**<br>Units 801-806, 8/F., Tower 1, Millennium City 1, 388 Kwun Tong Road, Kwun Tong, Kowloon. |
| **NEW TERRITORIES** | |
| **Sha Tin & Tai Po**<br>Rooms 304-313, 3/F., Sha Tin Government Offices, 1 Sheung Wo Che Road, Sha Tin, New Territories. | **Kwai Chung**<br>6/F., Kwai Hing Government Offices, 166-174 Hing Fong Road, Kwai Chung, New Territories. |
| **Tsuen Wan**<br>5/F., Tsuen Wan Government Offices, 38 Sau Lau Kok Road, Tsuen Wan, New Territories. | **Tuen Mun**<br>Unit 2, East Wing, 22/F., Tuen Mun Central Square, 22 Hoi Wing Road, Tuen Mun, New Territories. |

អាស័យដ្ឋានរបស់ការិយាល័យពាក់ព័ន្ធអាចនឹងមានការផ្លាស់ប្តូរ។ សម្រាប់ព័ត៌មានលម្អិត សូមចូលទៅកាន់គេហទំព័រ www.labour.gov.hk/eng/tele/Ir1.htm

គណនីម៉ែលសម្រាប់បញ្ហានានាដែលទាក់ទង នឹងអ្នកបំរើការតាមផ្ទះ fdh-enquiry@labour.gov.hk



# អ្នកជំនួយការងារផ្ទះនៅបរទេស

## សិទ្ធិនិងការការពារយោងតាមច្បាប់ការងារ



勞工處

Labour Department




## កិច្ចសន្យាការងារស្តង់ដារសម្រាប់អ្នកជំនួយការងារផ្ទះនៅបរទេស

កិច្ចសន្យាការងារស្តង់ដារបញ្ជាក់អំពីលក្ខណ្ឌការងាររបស់អ្នកជំនួយការងារផ្ទះនៅបរទេសដែលនៅក្នុងហុងកុង។**វាគឺជាឯកសារផ្លូវច្បាប់តែមួយគត់ ដែលត្រូវបានទទួលស្គាល់** ដោយរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុងសម្រាប់គោលបំណងនៃការជួលអ្នកជំនួយការងារផ្ទះនៅបរទេស។



យោងតាមកិច្ចសន្យាការងារស្តង់ដារអ្នកជំនួយការងារផ្ទះនៅបរទេស មានសិទ្ធិ៖

- ទទួលបានប្រាក់ឈ្នួលអប្បបរមាដែលត្រូវចេញដោយរដ្ឋាភិបាលហុងកុង(ប្រការទី 5(a) នៃកិច្ចសន្យា)
- ទទួលបានប្រាក់ឧបត្ថម្ភលើម្ហូបអាហារ ក្នុងករណីដែលនិយោជកពុំផ្តល់ម្ហូបអាហារដល់ពួកគេ (ប្រការទី 5(b))
- ទទួលបានទីកន្លែងស្នាក់នៅដោយឥតគិតថ្លៃ (ប្រការទី 5(b))
- ទទួលប្រាក់លើសោហ៊ុយលើការចំណាយត្រលប់មកមាតុភូមិវិញ (ប្រការទី 7(a))
- ការព្យាបាលជំងឺដោយឥតគិតថ្លៃ ដែលរួមបញ្ចូលទាំងការប្រឹក្សាយោបល់ផ្នែកវេជ្ជសាស្ត្រការថែទាំនៅក្នុងមន្ទីរពេទ្យនិងការព្យាបាលធ្មេញបន្ទាន់ផងដែរ (ប្រការទី 9(a))
- ច្បាប់ឈប់សម្រាកទៅលេងផ្ទះដោយមានប្រាក់ឈ្នួល ឬគ្មានប្រាក់ឈ្នួលដោយសោហ៊ុយលើ ការធ្វើដំណើរគឺជាចំណាយរបស់និយោជក (ប្រការទី 13)

## ប្រាក់ឈ្នួលអប្បបរមា



និយោជកត្រូវតែទូទាត់ជូនអ្នកជំនួយការងារផ្ទះនៅបរទេសរបស់ពួកគេ នូវប្រាក់ខែដែលមិនតិច ជាងប្រាក់ឈ្នួលអប្បបរមាដែលចេញដោយរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុងគិតនៅថ្ងៃចុះហត្ថលេខាលើកិច្ចសន្យា ។




## ការបង់ប្រាក់ឈ្នួល

ប្រាក់ឈ្នួលគួរត្រូវបានបង់ ក្នុងរយៈ**ពេលមិនលើសពី 7 ថ្ងៃ** បន្ទាប់ពីថ្ងៃធ្វើការចុងក្រោយនៃខែ នីមួយៗ ឬបន្ទាប់ពីការបញ្ចប់កិច្ចសន្យាការងារ ។



## ការផ្តល់ប្រាក់ឈ្នួលមិនគ្រប់ចំនួន

ប្រសិនបើប្រាក់ឈ្នួលដែលបានទទួលមានចំនួនតិចជាងចំនួនដែលបានចែងនៅក្នុងកិច្ចសន្យា ការងារនោះ អ្នកជំនួយការងារផ្ទះនៅបរទេសគួរតែ ៖

- បញ្ជាក់អំពីចំនួនដែលត្រឹមត្រូវជាមួយនិយោជក
- មិនទទួលស្គាល់ការទទួលប្រាក់ឈ្នួល ដែលនិយោជកបានផ្តល់ឱ្យ និង
- ក្នុងករណីផ្តល់ប្រាក់ឈ្នួលមិនគ្រប់ចំនួន រាយការណ៍ទៅកាន់ក្រសួងការងារឲ្យបានឆាប់រហ័ស បំផុតតាមដែលអាចធ្វើទៅបាន ។



## ការកាត់ប្រាក់ឈ្នួល

ការកាត់ប្រាក់ឈ្នួលត្រូវបានហាមឃាត់ លើកលែងតែ ៖

- ដោយសារការខូចខាត ឬការខាតបង់ទំនិញ ឬទ្រព្យសម្បត្តិរបស់និយោជកដោយសារការធ្វេស ប្រហែស ឬកំហុសរបស់អ្នកជំនួយការងារផ្ទះនៅបរទេស។ **ចំនួនទឹកប្រាក់ដែលត្រូវកាត់នៅក្នុងករណីនីមួយៗមិនត្រូវលើសពី 300 ដុល្លារហុងកុង ឡើយ** ។
- អវត្តមានពីការងារមិនលើសពីចំនួនសរុបដែលសមាមាត្រទៅនឹងរយៈពេលអវត្តមាន
- កាត់យកវិញពីប្រាក់ឱ្យខ្ចីមុនឬការទូទាត់ប្រាក់ឈ្នួលដែលបានបង់លើសចំនួន
- កាត់យកវិញពីប្រាក់កម្ចីដែលត្រូវបានផ្តល់ជូនស្ត្រីជំនួយការងារតាមផ្ទះ ដោយមានសំណើជា លាយលក្ខណ៍អក្សរពីពួកគេ។ល។

ទឹកប្រាក់កាត់សរុប លើកលែងការកាត់ប្រាក់សម្រាប់ការអវត្តមានពីការងារ ត្រូវតែមិនលើសពីពាក់ កណ្តាលនៃប្រាក់ឈ្នួលដែលត្រូវទូទាត់នៅក្នុងរយៈពេលដែលបានធ្វើការនោះឡើយ ។



## ថ្ងៃឈប់សម្រាក

អ្នកជំនួយការងារផ្ទះនៅបរទេស៖

- គួរតែមាន**ថ្ងៃសម្រាក** យ៉ាងតិច **1 ថ្ងៃ** ក្នុងចន្លោះរយៈពេល 7 ថ្ងៃ
- អាចធ្វើការតាមការស្ម័គ្រចិត្តនៅថ្ងៃសម្រាក ។

**និយោជកមិនត្រូវបង្ខំអ្នកជំនួយការងារផ្ទះនៅបរទេសឲ្យធ្វើការនៅថ្ងៃឈប់សម្រាកនោះទេ។**



## ថ្ងៃឈប់សម្រាកបុណ្យជាតិ

អ្នកជំនួយការងារផ្ទះនៅបរទេសមានសិទ្ធិទទួលបាន៖

- **ថ្ងៃឈប់សម្រាកបុណ្យជាតិ** និង
- ទូទាត់ប្រាក់សម្រាប់ថ្ងៃឈប់សម្រាកបុណ្យជាតិ ប្រសិនបើគាត់បានបម្រើការងារអស់រយៈពេល 3 ខែរួចហើយមុនថ្ងៃឈប់សម្រាកបុណ្យជាតិ ។

**មិនអនុញ្ញាតឲ្យមានការទូទាត់ប្រាក់ជំនួសឲ្យការផ្តល់ថ្ងៃឈប់សម្រាកបុណ្យជាតិនោះទេ ។**



ប្រសិនបើថ្ងៃសម្រាកបុណ្យជាតិត្រូវចំថ្ងៃដែលអ្នកជំនួយការងារផ្ទះត្រូវឈប់សម្រាកធម្មតាដែរនោះនោះថ្ងៃឈប់សម្រាកបុណ្យជាតិនឹងត្រូវលើកទៅថ្ងៃបន្ទាប់នៃថ្ងៃដែលគាត់ ឈប់សម្រាកធម្មតា ។

ប្រសិនបើអ្នកជំនួយការងារផ្ទះ ត្រូវធ្វើការនៅថ្ងៃឈប់សម្រាកបុណ្យជាតិការផ្លាស់ប្តូរកាលវិភាគនៃថ្ងៃឈប់សម្រាកបុណ្យជាតិនឹងត្រូវធ្វើឡើងក្នុងអំឡុងពេល **60** ថ្ងៃ មុនឬបន្ទាប់ពីថ្ងៃឈប់សម្រាកបុណ្យជាតិ។



## ច្បាប់ឈប់សម្រាកប្រចាំឆ្នាំ

អ្នកជំនួយការតាមផ្ទះមានសិទ្ធិទទួលបានច្បាប់ឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលបន្ទាប់ពីធ្វើការបានរយៈពេល12ខែជាមួយនិយោជកតែម្នាក់នោះ ក្នុងអត្រាដូចខាងក្រោម ៖

- អ្នកជំនួយការងារផ្ទះនៅបរទេសទទួលបានច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន7ថ្ងៃនៅកំឡុងពេលឆ្នាំទីមួយនិងនៅកំឡុងពេលឆ្នាំទីពីរនៃការបម្រើការងាររបស់គាត់
- ចាប់ពីឆ្នាំទីបីទៅ ចំនួនថ្ងៃនៃច្បាប់ឈប់សម្រាកប្រចាំឆ្នាំកើនឡើង 1 ថ្ងៃក្នុងមួយឆ្នាំរហូតដល់ ច្រើនបំផុត 14 ថ្ងៃ សម្រាប់មួយឆ្នាំ។



## ប្រាក់ឧបត្ថម្ភសម្រាប់ការព្យាបាលជំងឺ

អ្នកជំនួយការងារផ្ទះនៅបរទេសមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ការព្យាបាលជំងឺ ប្រសិន បើគាត់៖

- បានសន្សំចំនួនថ្ងៃឈប់សម្រាកព្យាបាលជំងឺមានប្រាក់ឈ្នួលគ្រប់ចំនួន ។
- ច្បាប់សម្រាកព្យាបាលជំងឺម្តងត្រូវសុំមិនលើសពី4ថ្ងៃជាប់គ្នាហើយ
- ច្បាប់សម្រាកព្យាបាលជំងឺដែលត្រូវសុំត្រូវមានវេជ្ជបញ្ជាត្រឹមត្រូវដើម្បីបញ្ជាក់។

អត្រាប្រាក់ឧបត្ថម្ភសម្រាប់ព្យាបាលជំងឺប្រចាំថ្ងៃមានចំនួនសរុបស្មើនឹងបួនភាគប្រាំនៃប្រាក់ឈ្នួលជាមធ្យមប្រចាំថ្ងៃរបស់អ្នកជំនួយការផ្ទះនៅបរទេស។



## ការឈប់សម្រាកមាតុភាព

អ្នកជំនួយការងារផ្ទះនៅបរទេសម្នាក់មានសិទ្ធិទទួលបានការឈប់សម្រាកមាតុភាព រយៈពេល 14 សប្តាហ៍ ប្រសិនបើនាងបានផ្តល់ការជូនដំណឹងដល់និយោជកអំពីការមានផ្ទៃពោះនោះហើយនិងបំណងរបស់នាងក្នុងការសុំឈប់សម្រាកមាតុភាព។ នាងមានសិទ្ធិទទួលបានប្រាក់ឈ្នួលពេលសម្រាកមាតុភាពក្នុងអត្រាប្រចាំថ្ងៃបួនភាគប្រាំ នៃប្រាក់ឈ្នួលប្រចាំថ្ងៃជាមធ្យមរបស់នាង ប្រសិនបើនាងបំពេញតាមលក្ខណៈវិនិច្ឆ័យដែលពាក់ព័ន្ធ។

**និយោជកត្រូវបានហាមឃាត់មិនឱ្យបណ្តេញចេញអ្នកជួយការងារផ្ទះដែលមានផ្ទៃពោះនៅពេលឈប់សម្រាកមាតុភាពឬឈប់សម្រាកឈឺឡើយ លើកលែងតែក្នុងករណីដែលនិយោជិតមានកំហុសធ្ងន់ធ្ងរ ។**